# ជើងក្រានប្រើប្រាស់ទូទៅ ជំនឿ និងពិធីផ្សេងៗ

មនុស្សចេះបង្កើតភ្លើងតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្ល៉េះ គឺដើម្បីចម្អិនអាហារផង និងសម្រាប់អាំងភ្លើងនៅពេលមានអាកាសធាតុត្រជាក់ផង និងសម្រាប់ការពារសត្វដែលកាចសាហាវនៅក្នុងព្រៃជាដើម។ល។ ជាក់ស្តែងដូចជាការធ្វើកំណាយបែបបុរាណវិទ្យានៅស្ថានីយ៍ ជូគុជៀន ជិតទីក្រុងប៉េកាំងនៃប្រទេសចិន ដែលគេសន្និដ្ឋានថា គឺជាទីតាំងរបស់ពួកអំបូរ Homo Erectus ក្នុងនោះគេបានរកឃើញសំណល់ធ្យូងនៃផេះជើងក្រានដែលជើងក្រាននោះ គឺជាប្រភេទជើងក្រានបែបសាមញ្ញដោយគ្រាន់តែយកដុំថ្មបីដុំមកធ្វើជាមុមជើងក្រានដើម្បីប្រើប្រាស់តែម្តង[១]។ ប៉ុន្តែតៗមកទៀតជើងក្រានក៏បានផ្លាស់ប្តូររូបរាងទៅតាមការច្នៃរបស់មនុស្សនៅពេលប្រើ។ រហូតមកដល់សម័យឥឡូវនេះ ការប្រើប្រាស់ជើងក្រានមានប្រភេទច្រើនបែប ច្រើនយ៉ាងខុសៗគ្នា ហើយនឹងមានតួនាទី ប្លែកៗគ្នាដែរ។ ម្យ៉ាងទៀតជើងក្រានក៏មានគេយកទៅប្រើប្រាស់ក្នុងជំនឿ និងពិធីផ្សេងៗផង។

ពាក្យ "**ជើងក្រាន**" មានន័យស្មើនឹងពាក្យ "**គ្រួ**" គឺជាពាក្យបុរាណដែលមានន័យថាជើងក្រាន ដោយមនុស្សយល់ថាផ្ទះមួយត្រូវមានជើងក្រានមួយជានិច្ច។ រីឯន័យមួយទៀតជើងក្រានជាប្រដាប់សម្រាប់តម្កល់ឆ្នាំងចម្អិនអាហារ[២]។

មនុស្សទូទៅយល់ថា គ្រួសារមួយជាផ្ទះ ហើយជាជើងក្រានមួយ។ សម្រាប់គ្រួសារឥណ្ឌានីមួយៗ ត្រូវតែមានជើងក្រានមួយជាចាំបាច់ គឺជាអគ្គិមួយ ដែលគេទុកអគ្គិនេះជាម្ចាស់នៃគេហដ្ឋាន។ ក្នុងអត្ថបទនេះនឹងបង្ហាញពីប្រភេទជើងក្រានមួយចំនួនដែលប្រើប្រាស់ប្រចាំថ្ងៃ និងក្នុងជំនឿ និងពីធីផ្សេងៗក្នុងស្រុកខ្មែរ ដែលប្រជាជនទូទៅសឹងតែពុំសូវចាប់អារម្មណ៍ពីសារៈសំខាន់របស់ជើងក្រាននោះទេ?

## ជើងក្រានប្រើប្រាស់ជាឧបករណ៍ដណ្តាំស្ល

តាមផ្ទះនិមួយៗត្រូវតែមានជើងក្រានជាចាំបាច់។ ការរៀបចំទីតាំងជើងក្រានក្នុងផ្ទះបាយ យើងសង្កេតឃើញមានប្លែកៗគ្នាច្រើនយ៉ាង ហើយហាក់ដូចជាតាមទម្លាប់របស់គ្រួសារផ្សេងៗផង ដោយអ្នកខ្លះរៀបចំទីតាំងដាក់ជើងក្រាននៅក្នុងផ្ទះបាយនៅខាងក្រោមផ្ទះ ខ្លះជាប់នឹងផ្ទះ ខ្លះដាច់ដោយឡែកចេញពីផ្ទះ និងខ្លះទៀតនៅលើផ្ទះជាដើម (រូបលេខ១)។

---

[១] John 1984: 56-57

[២] ពុទ្ធសាសនបណ្ឌិត ១៩៦៧: ៦០, ១៩៦

អត្ថបទដោយ៖ លោក ថាន់ មនោមយិទ្ធិ

ប្រភេទជើងក្រានមានច្រើនបែបណាស់ ដោយការបង្កើតនោះ គឺធ្វើឡើងទៅតាមតម្រូវការ និងការងាយស្រួលប្រើប្រាស់ ឬក៏អាចជាទំនៀមទម្លាប់ប្រពៃណីរបស់ អ្នកស្រុកៗ ប្រភេទជើងក្រានទាំងនោះមានដូចជា ជើងក្រានមុម៣ ជើងក្រានពៅ ជើងក្រានព្យួរ ជើងក្រានពងមូល ជើងក្រានឡូវកន្ទុយ និងជើងក្រានសៀមជាដើម(រូបលេខ២-៣)។ ប្រភេទជើងក្រានមុម៣ ជើងក្រានពៅ និងជើងក្រានព្យួរ គឺឃើញមានបង្ហាញលើចម្លាក់ប្រាសាទបាយ័ន្ត ផ្ទាំងគំនូរនៃវត្តរាជបូព៌ និងផ្ទាំងគំនូរព្រះវិហារវត្តក្រាំងលាវជាដើម(រូបលេខ៤-៥)។ ជាទូទៅ អ្នកស្រុកច្រើនប្រើប្រភេទជើងក្រានទាំងនេះ នៅពេលចូលព្រៃទៅរកអនុផលព្រៃឈើ ឬធ្វើដំណើររកស៊ីលក់ដូរផ្លូវឆ្ងាយ ដោយជើងក្រានទាំងនេះ គឺងាយស្រួលនឹងធ្វើសម្រាប់ដណ្តាំស្ល។

## ជើងក្រានក្នុងជំនឿ និងពីធីផ្សេងៗ

តាមទំនៀមជំនឿលើជើងក្រានរបស់អ្នកស្រុក ពិសេសនៅទីជនបទដែលនៅតែបន្តប្រតិបត្តិជំនឿនេះជាហូរហែរមកដល់បច្ចុប្បន្នជាក់ស្តែងដូចជា កិច្ចសែនជើងក្រាន (សែនជើងក្រានបិតស្រា សែនជើនក្រានលត់ដែត និងសែនជីនាងជើងក្រានៗលៗ) ពិធីសំពះជើងក្រានសូមកុំឱ្យកូនប្រុសស្រីគេងនោមយប់ និងពិធីទម្លាក់ជើងក្រានដែលគេធ្វើឡើងនៅពេលស្ត្រីសម្រាលកូនបញ្ចប់ការអាំងភ្លើងចំនួនបីថ្ងៃ ដោយមានយាយម៉បជាអ្នករៀបចំកិច្ចសែនព្រេងសម្រាប់ពិធីពន្ទត់ជើងក្រាន។

ចំពោះពិធីបុណ្យសពគេប្រើប្រាស់ជើងក្រានជាគ្រឿង បន្ទង និងជើងក្រានសម្រាប់ធ្វើកិច្ចនៅពេលដង្ហែសពៗ តាមទំនៀមចាស់ខ្លះ នៅពេលធ្វើពិធីដង្ហែសពចេញផុតផ្ទះភ្លាម គឺគេយកជើងក្រានមួយទៅបោកចោលនៅខាងក្រៅផ្ទះ ឬរបងផ្ទះ ហើយមានអ្នកខ្លះថែមទាំងយកក្អមទឹក ឬឆ្នាំងដីទៅបោកចោលជាមួយនឹងជើងក្រាននោះដែរ។ យើងដឹងថាជើងក្រានមានន័យស្មើនឹងគ្រួសារ ដូច្នេះចំពោះបុគ្គលដែលស្លាប់ទៅគេទុកថាជាអ្នកដែលបែកគ្រួសារ ពោលគឺមិនរាប់ថាជាអ្នកដែលនៅក្នុងផ្ទះជាមួយគ្នាទៀតឡើយ។ ការបោកជើងក្រាននេះ ក៏ហាក់ដូចជាកិច្ចបញ្ចៀសឧបទ្រពចង្រៃផ្សេងៗផង ព្រោះពេលខ្លះគេត្រូវធ្វើកិច្ចបោកជើងក្រានចោលនៅត្រង់ផ្លូវបំបែក[៣]។ ទំនៀមយកជើង ក្រានទៅចោលជាមួយសពរបៀបខាងលើនេះ ពុំមែនមានតែចំពោះខ្មែរនោះទេ ចំពោះជនជាតិភាគតិចខ្លះ ដូចជាជន-ជាតិជ្រាយជាដើម ពីមុនមកពេលមានមនុស្សស្លាប់នៅក្នុងផ្ទះ គេត្រូវដុតផ្ទះនោះចោល គឺគេមិនឱ្យមនុស្សស្លាប់ក្នុងផ្ទះទេ ព្រោះចង្រៃដល់ផ្ទះ ហើយគេត្រូវទៅសង់ថ្មីផ្សេងទៀត។

[៣] លី សុវី ១៩៩៤: ៣៦

អត្ថបទដោយ៖ លោក ថាន់ មនោមយិទ្ធិ

ប៉ុន្តែមកដល់សព្វថ្ងៃគេពុំរើផ្ទះចោលទេ គឺគេយកជើងក្រានទៅចោលនៅក្នុងខ្ទមក្រៅផ្ទះនោះវិញ ដើម្បីជាការឧបកិច្ច[៤]។

ដោយឡែកក្នុងពិធីឡើងផ្ទះថ្មី គេប្រើជើងក្រាន ជាគ្រឿងរណ្តាប់ធ្វើពិធីឡើងផ្ទះ ដោយគេយកជើងក្រានទៅដាក់នៅទិសខាងកើត[៥]។ បើតាមទម្លាប់អ្នកស្រុក គេរៀបចំដាក់ជើងក្រានក្នុងផ្ទះថ្មីនៅត្រង់កន្លែងមួយក្នុងផ្ទះបាយ ហើយគេធ្វើកិច្ចនេះនៅថ្ងៃឡើងផ្ទះថ្មីនោះតែម្តង ដោយគេជឿថាបើរៀបចំជើងក្រានថ្មីចំថ្ងៃខែមិនល្អនឹងនាំឱ្យភ្លើងឆេះផ្ទះ។

តាមរបាយការណ៍របស់ឧកញ៉ាពិទូ ឈឹម ក្រសេម ដែលរៀបរាប់អំពីព្រះរាជាពិធីទ្វាទសមាស សរសេរក្នុង (គ.ស.១៩៥១) ឃើញថា ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល គឺក្រុម បារគូត្រូវមកធ្វើកិច្ចផ្សេងៗតាមទំនៀមព្រាហ្មណ៍នៅនឹងទីព្រះស្រែមុនៗ ក្នុងនោះ ***"ហោមពិធី"*** ជាកិច្ចមួយដែលបារគូត្រូវធ្វើ ដោយក្រុមបារគូត្រូវរៀបចំកន្លែងមួយ ដោយយកដីមកបូកឱ្យមានរាងថ្នាក់ៗបួនជ្រុងស្មើចំនួន៣ជាន់ កម្ពស់១ហត្ថ៥ធ្នាប់ ហើយគេយកអាចម៍គោស្រស់ទៅបូកឱ្យស្អាត។ រណ្តៅនោះហៅថា ***"ហោមកុណ្ឌ"*** មានន័យថារណ្តៅបូជាព្រះភ្លើង ដោយមានបង់ទៅក្នុងភ្លើងនូវចម្រៀកឧសតូចៗ (ឈើពុទ្រា ឬសង្កែ), ស្មឹកឈើច្រើនប្រភេទ, ទឹកដោះគោ និងទឹកឃ្មុំជាដើម គឺត្រូវធ្វើតាមក្រិត្យក្រមបែបព្រាហ្មណ៍[៦]។ បើពិនិត្យមើលទៅឃើញថា ក្នុងកិច្ចបូជាព្រះភ្លើងនេះ គឺគេប្រើពំនូកដីដែលរៀបចំស្អាតបាត ដើម្បីថ្កល់ភ្លើងឱ្យខ្ពស់ផុតពីដី ហើយពុំដឹងហៅទម្រភ្លើងនោះថាជាអ្វីប្រាកដទេ។ តែដោយសារពំនូកដីនោះសម្រាប់ដាក់ភ្លើង ដូច្នេះក្នុងទីនេះខ្ញុំសូមហៅបណ្តោះអាសន្នថាជាជើងក្រានដែរ។ មកដល់បច្ចុប្បន្ននេះលែងឃើញមានពិធីបូជាព្រះភ្លើង និងជើងក្រានរបៀបនោះទៀតហើយ។ ប៉ុន្តែបើយើងពិនិត្យមើលទៅលើចម្លាក់ខ្លះនៅតាមជញ្ជាំងប្រាសាទបាយ័ន្ត (ស.វ.ទី១២) ឃើញថាមានពួកព្រាហ្មណ៍កំពុងអង្គុយធ្វើពិធីបូជាព្រះភ្លើង គឺទំនងជាអារដែសម្រក់ឈាមចូលទៅក្នុងភ្លើងដែលកំពុងឆេះនៅក្នុងជើងក្រាន ដែលមានរូបរាងដូចទៅនឹងជើងក្រានបានរៀបរាប់ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លខាងលើនេះដែរ(រូបលេខ៦)។

សម្រាប់ក្នុងពិធីឆ្លងវ័យដូចជា កោរជុក, បួសនាគ, ចេញម្លប់, រៀបការ គឺគេមិនដែលចោលពិធីមួយដែលជាកិច្ចទាក់ទងនឹងការប្រើប្រាស់ជើងក្រាន ពោលគឺពិធីធ្វើធ្មេញ ឬពិធីដាប់ធ្មេញ ដ្បិតពិធីនេះ គឺចាំបាច់ណាស់ចំពោះសាមុីខ្លួនដែលធ្វើពិធីដូចខាងលើ ក្នុង

---

[៤] ប្រសាសន៍លោកសាស្ត្រចារ្យ អាំង ជូលាន

[៥] ចងក្រងដោយក្រុមជំនុំទំនៀមទម្លាប់ខ្មែរ: ១-៨

[៦] ឈឹម ក្រសេម ១៩៥១: ១១៩-១២២

បំណងឱ្យសាម៉ីខ្លួនចេះប្រើពាក្យពេចន៍និយាយស្ដីល្អៗ ស្របទៅនឹងសង្គមឱ្យញាតិមិត្តគេចូលចិត្តរាប់អាន។ ក្នុងកិច្ចធ្វើធ្មេញនេះ យើងសង្កេតឃើញគេយកជើងក្រានមោង ឬជើងក្រានលៅ ឬជើងក្រានមុមបី មកប្រើក្នុងពីធីនេះ ដើម្បីជាឧបករណ៍សម្រាប់ស្ងថ្នាំ ដោយគេថ្កល់ឆ្នាំងថ្នាំពីលើជើងក្រាន និងជំនីកនៅក្នុងឆ្នាំងដី ដើម្បីទុកសម្រាប់តម្រឹមធ្មេញ ហើយដូងសម្រាប់ខ្ពុរមាត់ពេលដែលតម្រឹមធ្មេញរួច(រូបលេខ៧-៨)។

សរុបមកជើងក្រានមានសារសំខាន់ណាស់សម្រាប់ដណ្ដាំស្ងប្រចាំថ្ងៃផង និងមានតួនាទីប្រើនៅក្នុងពិធី និងជំនឿផ្សេងៗផង។ រហូតមកដល់បច្ចុប្បន្នរាល់ពិធីទាំងនេះ សង្កេតឃើញថា គេនៅតែយកជើងក្រានមកប្រើដដែលទៅតាមពិធីនីមួយៗ។ គួរជ្រាបដែរថា ជើងក្រាន និងគ្រួសារមានន័យប្រហាក់ប្រហែលគ្នា នេះទំនងជាជើងក្រានហើយនឹងគ្រួសារមិនអាចផ្ដាច់ចេញពីគ្នាបាន ដ្បិតក្នុងគ្រួសារ ឬក៏ផ្ទះនីមួយៗតែងមានជើងក្រានជានិច្ច។

## ឯកសារយោងៈ


**ពុទ្ធសាសនបណ្ឌិត្យ**

១៩៦៧. វចនានុក្រមខ្មែរ, ភ្នំពេញ

**លី សុវីរ**

១៩៩២. *ពិធីបុណ្យខ្មោចសតវត្សទី១៩ និងដើមសតវត្សទី២០*, វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ ក្រសួងអប់រំ, ភ្នំពេញ

ឈឹម ក្រសេម

១៩៥១. *រៀបរាប់អំពីព្រះរាជពិធីទ្វាទសមាស*,ភ្នំពេញ

**John, Gowlett.**

1984. *Ascentto Civilization,* New York


អត្ថបទដោយៈ លោក ថាន់ មនោមយិទ្ធិ

## អត្ថបទ៖ជើងក្រានប្រើប្រាស់ទូទៅ ជំនឿ និងពិធីផ្សេងៗ



រូបលេខ១៖ ទីតាំងជើងក្រាននៅលើផ្ទះ
លយចេញទៅខាងស្តាំ



រូបលេខ២៖ ប្រភេទជើងក្រានពោ



រូបលេខ៣៖ ប្រភេទជើងក្រានព្យួរ



រូបលេខ៤៖ គំនូរជើងក្រានព្យួរក្នុងរឿងព្រះវេស្សន្តរ



រូបលេខ៥៖ ជើងក្រានមុមបី ចម្លាក់ប្រាសាទបាយ័ន្ត



រូបលេខ៦៖ ព្រាហ្មណ៍កំពុងធ្វើបូជាព្រះភ្លើង
ដោយប្រើជើងក្រានរាងជាថ្នាក់ៗ



រូបលេខ៧៖ ជើងក្រានមុមបីស្ងួថ្នាំ



រូបលេខ៨៖ អាចារ្យកំពុងធ្វើពិធីដាប់ធ្មេញ

អត្ថបទដោយ៖ លោក ថាន់ មនោមយិទ្ធិ